00637126

E22

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 21 / 01 / 2011
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់មេធាវីការពារក្ដី អ្នកស្រី អៀង ធីរិទ្ធ ពាក់ព័ន្ធនឹងដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈ ដើម្បីរៀបចំសវនាការ**

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវីរបស់ អៀង ធីរិទ្ធ** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក ផាត់ ពៅស៊ាង | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| កញ្ញា Diana ELLIS QC | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | **មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី** |
| | ចៅក្រម Silvia CARTWRIGHT | **ដើមបណ្ដឹងរដ្ឋប្បវេណីគ្មានតំណាងទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | |

00637127



## I. សេចក្តីផ្តើម

១. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១, អង្គជំនុំជម្រះសាលាដំបូងបានចេញ "ដីកាបង្គាប់ភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ" (ដីកា)[1]។

២. នៅក្នុងដីកា, អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់បណ្តាភាគីឱ្យផ្តល់ព័ត៌មានរបស់សាក្សីដែលភាគីមានបំណងចង់ដាក់នៅក្នុងបញ្ជីសាក្សីរបស់ខ្លួន។ ព័ត៌មានទាំងនោះត្រូវមាន:

(ii) អាសយដ្ឋានបច្ចុប្បន្ន និង/ឬព័មានលំអិតសម្រាប់ទំនាក់ទំនង។

(iv) វិធានការការពារដែលមានជាធរមាន ព្រមទាំងឯកសារដែលជាសេចក្តីសម្រេចទាក់ទងនឹងវិធានការការពារទាំងនោះ។

(viii) ប្រភេទនៃសម្បថដែលត្រូវធ្វើ។

៣. មេធាវីការពារក្តីយល់ឃើញថាវាមិនអាចធ្វើទៅកើតទេក្នុងការផ្តល់នូវព័តមានដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ២ ខាងលើនេះ។

## II សេចក្តីសន្និដ្ឋាន

៤. មេធាវីការពារក្តីស្នើសុំឱ្យពិចារណាថា: វាមិនអាចផ្តល់នូវព័តមានទាំងអស់នោះបានទេ ដោយសារតែវាត្រូវបានហាមឃាត់យ៉ាងច្បាស់ពីសំណាក់ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនអោយបំពេញកិច្ចស៊ើបសួរដោយខ្លួនឯងនោះទេ។សហចៅក្រមស៊ើបអង្កេតបានប្រាប់ដល់មេធាវីការពារក្តីយ៉ាងដូច្នេះថា:

> [អំណាចក្នុងការស៊ើបសួរត្រូវប្រគល់ឲ្យតែសហចៅក្រមស៊ើបអង្កេតឯករាជ្យពីររូបប៉ុណ្ណោះ ហើយមិនឲ្យទៅភាគីឡើយ[2] ។

---

[1] អជសដ, ដីកាបង្គាប់ភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ: E9 ។ឯកសារនេះត្រូវបានជូនដំណឹងដល់បណ្តាភាគីនៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១១។

[2] កសចស, ការឆ្លើយតបទៅនឹងលិខិតរបស់លោក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ស្តីពីកិច្ចស៊ើបសួរ, ថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០៨, ឯកសារលេខ: A110/I ។

៥. មេធាវីការពារក្តីចាត់ទុកដោយខ្លួនឯងថា មេធាវីការពារក្តីនៅតែមានកាតព្វកិច្ចគោរពតាមនូវការហាមឃាត់នេះនៅឡើយទេ វៀរលែងតែអង្គជំនុំជម្រះបានសម្រេចផ្សេងពីនេះ ដូច្នេះមេធាវីការពារក្តីមិនមានសិទ្ធិដើម្បីទាក់ទងសាក្សីទាំងនោះ ដែលខ្លួនមានបំណងដាក់នៅក្នុងបញ្ជីសាក្សីបានទេ។

## III សំណូមពរ

៦. សំរាប់ហេតុផលទាំងអស់នេះ វាមិនអាចទៅរួចទេដើម្បីកំណត់អំពីអាសយដ្ឋានបច្ចុប្បន្ន និង/ឬព័ត៌មានលំអិតសម្រាប់ទំនាក់ទំនង និង ប្រភេទនៃសម្បថដែលត្រូវធ្វើនោះបានឡើយ។ លើសពីនេះទៀតនោះ ដោយហេតុថាសេចក្តីសម្រេចអំពីវិធានការការពារត្រូវបានគេដាក់ជាផ្នែក "សម្ងាត់បំផុត" នៃសំណុំរឿង ហើយដែលមេធាវីការពារក្តីមិនអាចទទួលបានព័ត៌មានទាំងនេះបានទេ ។ មេធាវីការពារក្តីមិនមានសិទ្ធិដើម្បីផ្តល់ព័ត៌មានចំពោះវិធានការការពារដែលមានជាធរមានរបស់សាក្សីនៅក្នុងបញ្ជីសាក្សីរបស់ខ្លួននោះឡើយ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | [signature and stamp: AVOCAT / ATTORNEY AT LAW / KINGDOM OF CAMBODIA] |